# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2013, 12:11
CMS/CFO: Ly Bunloung

# សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្ដឹងសាទុក្ខផ្សេងៗ របស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២

**ដាក់ដោយ:**

**មេធាវីការពារក្ដី នួន ជា:**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSENSWEIG

Forest O'NEILL-GREENBERG

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

អនុលោមតាមវិធាន ១០៤(១), ១០៤(៤) និង ១០៥(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") សូមដាក់សារណាតបភ្លាមៗនេះ ("សារណាតប") ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ("ចម្លើយតប")[1] ដូចខាងក្រោម៖

1. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាថ្មីចំពោះការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[2]។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខភ្លាមៗមួយប្រឆាំងនឹងសេចក្តីសម្រេចនេះ ("បណ្តឹងសាទុក្ខ")[3] ហើយនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ បានដាក់សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខនោះ[4]។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបមួយ។ ទោះបីមេធាវីការពារក្តីបានជំទាស់ទៅនឹងការចោទប្រកាន់ជាច្រើននៅក្នុងការឆ្លើយតបនោះក៏ដោយ ក៏មេធាវីការពារក្តីសូមដាក់សារណាតបភ្លាម ក្នុងគោលបំណងកែតម្រូវកំហុសឆ្គងសំខាន់ៗមួយចំនួនតូច។

2. ទីមួយ សម្រាប់ជាកំណត់ហេតុ មេធាវីការពារក្តីបានកត់សម្គាល់ថា ទោះបីនៅក្នុងបណ្តឹងសាទុក្ខ ឬ នៅកន្លែងណាក៏ដោយ ក៏ នួន ជា តែងតែ "ប្រឆាំង" ជានិច្ចទៅនឹងការចោទប្រកាន់ពីតួនាទីរបស់គាត់នៅ

---

[1] ឯកសារលេខ **E284/4/3**, "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា", ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ("ចម្លើយតប")។

[2] ឯកសារលេខ **E284**, "សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣", ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")។

[3] ឯកសារលេខ **E284/4/1**, "បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី", ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខ")។

[4] ឯកសារលេខ **E284/4/2**, "សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ("សារណាបន្ថែម")។

មន្ទីរ ស២១[5]។ បញ្ហានៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការចោទប្រកាន់នានាដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលបានចោទប្រកាន់ នួន ជា យ៉ាងច្បាស់ថាគាត់មានតួនាទីសំខាន់ខុសប្លែកពីគេនៅមន្ទីរ ស២១[6]។ ជំហររបស់មេធាវីការពារក្តីគឺថា ការចោទប្រកាន់នេះបង្ហាញថា មន្ទីរ ស២១ មិនមែនតំណាងឲ្យដីកាដំណោះស្រាយជារួមទេ[7]។ តួនាទី*ជាក់ស្តែង*របស់ នួន ជា នៅមន្ទីរ ស២១ គឺមិនពាក់ព័ន្ធទាល់តែសោះ ហេតុនេះហើយវាមិនមែនជាកម្មវត្ថុសម្រាប់យកមកវិភាគនៅក្នុងបណ្តឹងសាទុក្ខនេះទេ។ មេធាវីការពារក្តីកត់សម្គាល់ថា បណ្តឹងសាទុក្ខពិតជាពិភាក្សាពីតួនាទីជាក់ស្តែងរបស់ នួន ជា ដោយថៃដន្យមែន ដោយសារវាពាក់ព័ន្ធនឹងសាក្សីដែលអង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅមកផ្តល់សក្ខីកម្មដើម្បីវិនិច្ឆ័យចំពោះ មន្ទីរ ២១។ បណ្តឹងសាទុក្ខសង្កត់ធ្ងន់ទៅលើភាពចាំបាច់ដែលត្រូវតតាំងទៅនឹងភាពជឿជាក់បាននៃការអះអាងរបស់ ឌុច ដែលថា គាត់បានរាយការណ៍ឲ្យ នួន ជា និងការអះអាងពាក់ព័ន្ធមួយទៀតរបស់គាត់ដែលថា សុន សេន លែងពាក់ព័ន្ធនៅមន្ទីរ ស២១ ទៀត ក្រោយថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៧[8]។ ចំណុចទាំងពីរនេះផ្ទុះបញ្ចាំងពីជំហរស៊ីសង្វាក់គ្នារបស់មេធាវីការពារក្តីដែលថា នួន ជា ពុំមានការទទួលខុសត្រូវនៅមន្ទីរ ស២១ ទេ។

3. ទីពីរ ទស្សនៈនានាដែលមេធាវីការពារក្តីបានលើកឡើងពីមុន ពាក់ព័ន្ធនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយនោះ ពុំមានឥទ្ធិពលទៅលើការសម្រេចនៅក្នុងបណ្តឹងសាទុក្ខនេះទេ[9]។ មេធាវីការពារក្តីកត់សម្គាល់ដោយចំអកចំពោះសហព្រះរាជអាជ្ញាដែលបានប្រើប្រាស់គោលការណ៍មួយ ដែលពួកគេធ្លាប់បានបដិសេធ ក្នុងគោលបំណងបង្ហាញថា មេធាវីការពារក្តីត្រូវបានរារាំងមិនឲ្យលើកឡើងនូវទឡ្ហីករណ៍មួយ (ដែលពួកគេជឿថា) ពុំស៊ីសង្វាក់គ្នាទៅនឹងជំហរពីមុន[10]។ ការពិត ពុំមានវិធានណាមួយ “រារាំង” មិនឲ្យភាគីកែប្រែជំហររបស់ទៅតាមពេលវេលានោះទេ ដែលនេះជារឿងធម្មតាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីផ្នែកព្រហ្មទណ្ឌ។ មានឯកសារយោងតាមច្បាប់ព្រហ្មទណ្ឌតែពីរគត់ ដែល

---

5 ចម្លើយតប, កថាខណ្ឌ ២១។

6 *សូមមើលឧទាហរណ៍*, ឯកសារលេខ **D427**, “ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ (“ដីកាដំណោះស្រាយ"), កថាខណ្ឌ ៨៤៩ ដល់ ៨៧៤។

7 បណ្តឹងសាទុក្ខ, កថាខណ្ឌ ៦៩។

8 បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៦ ដល់ ៧៩។

9 ចម្លើយតប, កថាខណ្ឌ ៦ ដល់ ៧។

10 *សូមមើល* ចម្លើយតប, ជើងទំព័រ ១៣ និងសារណាពីមុនៗដែលបានដកស្រង់នៅក្នុងនោះ។

សហព្រះរាជអាជ្ញាបានដកស្រង់យកមកសំអាង ពាក់ព័ន្ធនឹងការមិនទទួលបណ្ដឹងជាថ្មី (collateral estoppel) ដែលហាមឃាត់មិនឲ្យដាក់បណ្ដឹងជាថ្មីចំពោះបញ្ហានានាដែលតុលាការបានសម្រេចស្ថាពររួចហើយនោះ[11]។

4. នៅក្នុងកាលៈទេសៈណាក៏ដោយ ពុំមានចំណុចណាមួយនៅក្នុងបណ្ដឹងសាទុក្ខមិនស៊ីសង្វាក់គ្នាទៅនឹងជំហរពីមុនរបស់មេធាវីការពារក្ដីទេ។ ដូចដែលបណ្ដឹងសាទុក្ខបានលើកឡើងយ៉ាងច្បាស់រួចហើយគឺថា វាជាបទពិសោធន៍នៃការជំនុំជម្រះ ដែលបណ្ដាលឲ្យមេធាវីការពារក្ដីសន្និដ្ឋានថា ខ្លួនលែងគាំទ្រដល់ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយទៀតហើយ[12]។ មេធាវីការពារក្ដីបានគាំទ្រដល់ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅ ខែ តុលា ឆ្នាំ ២០១១ ដែលមានរយៈពេលជាច្រើនសប្ដាហ៍មុនពេលសវនាការស្ដាប់ភស្តុតាងបានចាប់ផ្ដើមទៅទៀត[13]។ នៅខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្ដីគ្រាន់តែជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលសុំបន្ថែម មន្ទីរ ស២១ ទៅក្នុង

---

[11] ចម្លើយតប, កថាខណ្ឌ ៦ និង ជើងទំព័រ ១០។ ទម្រង់ដទៃទៀតនៃការមិនទទួលបណ្ដឹងដដែលដែលសហព្រះរាជអាជ្ញាបានដកស្រង់មិនអាចអនុវត្តលើអង្គហេតុទាំងនេះបានទេ ទោះបីទម្រង់ទាំងនោះត្រូវបានយកទៅអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ។ *រឿងក្ដី រដ្ឋ New Hampshire តទល់នឹងរដ្ឋ Maine*, សំណុំរឿងលេខ 532 U.S. 742 (ឆ្នាំ ២០០១) អនុវត្តនៅដែលភាគីមួយជោគជ័យក្នុងការប្រកាន់ជំហរមួយ ហើយបន្ទាប់មកបែរជាប្រកាន់ជំហរផ្ទុយទៅវិញ។ យុត្តិសាស្ត្រនៃតុលាការដែលបានដកស្រង់នោះក៏បានអនុវត្តស្រដៀងគ្នាដែរ នៅពេលដែលភាគីជំទាស់នឹងការដាក់បណ្ដឹងជាថ្មីត្រូវបានអះអាងថាបានទទួលប្រយោជន៍ពីជំហរពីមុខរបស់ខ្លួន។ *សូមមើល* ចម្លើយតប ជើងទំព័រលេខ ១១។ តែសហព្រះរាជអាជ្ញាមិនដែលជំទាស់នឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទេ លើកលែងតែលក្ខខណ្ឌរបស់វា ហេតុនេះមេធាវីការពារក្ដីមិនដែល "ជោគជ័យ" ឬបានទទួលប្រយោជន៍ពីការគាំទ្រដល់ការបំបែកនេះទេ។ *សូមមើល* ឯកសារលេខ **E124/1**, "សេចក្ដីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើពាក្យ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង", ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៤។ *In re Kane*, 628 F. 3d 631 (3d Cir. 2010) តម្រូវឲ្យមិនមានភាពស៊ីសង្វាក់ដែលមិនអាចសម្របសម្រួលបាន ដែលមិនត្រូវបានបង្ហាញនៅក្នុងករណីនេះទេ (*សូមមើល* កថាខណ្ឌ ៤ *ខាងក្រោម*) និងមិនមានសុច្ចរិតភាព ដែលសហព្រះរាជអាជ្ញាមិនអាចអះអាងបាន។ *រឿងក្ដី Boizard តទល់នឹង E.C. Commission,* [1982] 1 C.M.L.R. 157 បានអនុវត្តស្រដៀងគ្នា នៅពេលដែលភាគីមួយ" នាំឲ្យភាគីមួយទៀត "យល់ខុស" ចំពោះអង្គហេតុជាក់ស្ដែង ដែលភាគីជំទាស់បានយកមកសំអាង។ *សូមមើលដូចខាងលើ* ទំព័រ ១៧១ (ភាសាអង់គ្លេស)។

[12] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ១២ ដល់ ២១។

[13] ឯកសារលេខ **E124/5**, "ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី", ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១។

វិសាលភាពនៃសំណុំរឿង ០០២/០១[14] ដែលនេះជាជំហរមួយដែលមេធាវីការពារក្ដីនៅតែបន្ដប្រកាន់យក[15]។ ភាពសមហេតុសមផលនៃការសម្រេចបំបែកនីតិវិធីមិនត្រូវបានដាក់ជាបញ្ហានៅឡើយទេ រហូតទាល់តែមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនេះនៅ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលតម្រូវឱ្យវាយតម្លៃសាជាថ្មីចំពោះបញ្ហានៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី *ជាថ្មី (de novo)* ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើយយ៉ាងត្រឹមត្រូវ[16]។ មេធាវីការពារក្ដីបានធ្វើការវាយតម្លៃនោះ ហើយមានសេចក្ដីសន្និដ្ឋានមួយផ្សេងទៅវិញ។ ពុំមានចំណុចណាមួយនៅក្នុងសេចក្ដីសម្រេចនោះ ដែលពុំសមស្របនោះទេ[17]។

5. ទីបី មេធាវីការពារក្ដីបានគាំទ្រយ៉ាងពេញលេញចំពោះទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយគឺមិនស្របទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌នោះទេ[18]។ មេធាវីការពារក្ដីបានលើកឧទាហរណ៍ជាក់លាក់នានាដែលថា ការដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ចេញការកំហិតផ្សេងៗពាក់ព័ន្ធនឹងការសួរដេញដោលសាក្សី[19] បានប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការសាកសួរសំណួរលើអង្គហេតុដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទចោទនានាដែលបានលើកឡើងនៅក្នុងសំណុំរឿង ០០២/០១[20]។ ដោយមិនដោះស្រាយចំពោះទឡ្ហីករណ៍ទាំងនេះ សហព្រះរាជអាជ្ញាបានលើកឡើងវិញអំពីចំណុចទូទៅដដែលៗអំពី

---

[14] ឯកសារលេខ **E163/5/1/4**, "សារណាឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ភ្លាមៗរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[15] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៥៦ ដល់ ៧១។

[16] ឯកសារលេខ **E284/2/1**, "បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១" ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្ដឹងសាទុក្ខរបស់ ក.ស.ព"), កថាខណ្ឌ ២៣។

[17] នៅក្នុងរឿងប្រឌិតដែលអាចក្លាយជាការពិតមួយ សេដ្ឋកិច្ចវិទូចក្រភពអង់គ្លេសដ៏ល្បីល្បាញម្នាក់ឈ្មោះ John Maynard Keynes ធ្លាប់ត្រូវបានប្រឈមមុខនឹងការជំទាស់មួយលើកឡើងថា វិទូរូបនេះលើកទស្សនៈមិនស្របគ្នាឡើយ។ Keynes បានឆ្លើយតបវិញយ៉ាងកំបុតថា៖ "ពេលដែលខ្ញុំរកឃើញភស្ដុតាងថ្មី ខ្ញុំបានប្ដូរចិត្តវិញ។ តើលោកនឹងធ្វើយ៉ាងម៉េចដែរ?"។

[18] *សូមមើល* ចម្លើយតប, កថាខណ្ឌ ៨ ដល់ ១០។

[19] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ១៤។

[20] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ១៥ ដល់ ១៦។

បញ្ហា "រចនាសម្ព័ន្ធ" នៅក្នុងសវនាការដែលកំពុងដំណើរការទៅមុខ[21] បន្ទាប់បានអះអាងដោយត្រង់ៗថា មេធាវីការពារក្ដីបានផ្ដល់នូវ "ការចង្អុលបង្ហាញភស្តុតាងទាក់ទងអង្គហេតុ និងអង្គច្បាប់តិចតួចបំផុត" នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន[22]។ មេធាវីការពារក្ដី "សំអាងទៅលើការចំណុចនានាដែលខ្លួនបានដកស្រង់ចេញពីសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង" ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ដោយប្រយោលរួចមកហើយ[23] គឺថា ដោយសារសេចក្ដីសម្រេចដែលត្រូវបានជំទាស់មិនទាំងបានទទួលស្គាល់ថា មានការលើកឡើងពីការជំទាស់ទាំងនោះផងទេ[24]។ អ្វីៗដែលនៅសេសសល់សម្រាប់ឲ្យមេធាវីការពារក្ដីត្រូវធ្វើនោះ គឺត្រូវអះអាងជាថ្មីពីការជំទាស់របស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អង្គជំនុំជម្រះនេះ។

6. ទីបួន សហព្រះរាជអាជ្ញាបានជំទាស់ដោយចាត់ទុកជា "ការរំលោភផ្នែកសីលធម៌" ចំពោះការលើកឡើងថា បទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តនៅមន្ទីរ ស២១ មានភាពសមហេតុផលដោយសារភាពចាំបាច់ផ្នែកយោធា។ តែរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលជាមហាអំណាចតែមួយគត់របស់ពិភពលោក ដែលជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ និងជាអ្នកគាំទ្រសាលាក្ដីនេះ បានអះអាងអំពីអំណាចស្របច្បាប់ដើម្បីសម្លាប់ជនស៊ីវិលស្លូតត្រង់រាប់ពាន់នាក់ ដោយបទបញ្ជានីតិប្រតិបត្តិទៅលើទឹកដីនៃរដ្ឋមួយដែលមិនស្ថិតក្នុងសង្គ្រាម ក្នុងគោលបំណងដើម្បីលុបបំបាត់ការគំរាមកំហែងផ្នែកសន្តិសុខតាមការស្រមើស្រមៃរបស់ខ្លួន[25]។ ការគំរាមកំហែងនោះរួមទាំងប្រជាពលរដ្ឋ ស.រ.អា ដែលមិនស្ថិតនៅក្នុង "កងកម្លាំងប្រដាប់អាវុធបដិបក្ខ" ណាមួយដែលមានការរៀបចំ[26]។ រដ្ឋាភិបាល ស.រ.អា អះអាងថា អំណាចនេះមានក្នុងទម្លាប់អនុវត្តន៍របស់រដ្ឋរាប់ទសវត្សរ៍មកហើយ[27] ដែលពាក់ព័ន្ធទៅនឹងស្ថានភាព និង

---

21 ចម្លើយតប, កថាខណ្ឌ ៩។

22 ចម្លើយតប, កថាខណ្ឌ ៨។

23 ចម្លើយតប, កថាខណ្ឌ ១៥។

24 បណ្ដឹងសាទុក្ខ, កថាខណ្ឌ ២២ ដល់ ២៥។

25 បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៨២ ដល់ ៨៣ និង ជើងទំព័រ ១៦៦។

26 ចម្លើយតប, កថាខណ្ឌ ២៥។

27 "ភាពស្របច្បាប់នៃប្រតិបត្តិការសម្លាប់មនុស្សប្រឆាំងចំពោះប្រជាពលរដ្ឋ ស.រ.អា ដែលជាមេដឹកនាំប្រតិបត្តិការជាន់ខ្ពស់នៃក្រុម Al-Qa'ida ឬកងកម្លាំងដែលពាក់ព័ន្ធ (ឯកសារស របស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក, ឆ្នាំ ២០១២)។

ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ[28]។ សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍ថា "ការកំណត់ជាបទល្មើសតាមផ្លូវច្បាប់ដែលសក្តិសមបំផុត" ចំពោះការចោទប្រកាន់នានាពាក់ព័ន្ធនឹង មន្ទីរ ស២១ គឺ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" តែនៅតែចង់បញ្ចូលមន្ទីរ ស២១ ឲ្យបានច្បាស់ ដោយសារវាធ្វើឲ្យមានការវិនិច្ឆ័យទៅលើការបំពារបំពានធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[29]។ ទោះបីបទដ្ឋានទ្វេរ (double standard) ដែលអាចអនុវត្តបានចំពោះយុទ្ធនាការប្រឆាំងនឹងភេរវកម្មរបស់អ្នកនយោបាយអាមេរិកដែលបានទទួលរង្វាន់ណូបែលសន្តិភាព លែងជាការគួរឲ្យភ្ញាក់ផ្អើលដល់មនុស្សទូទៅក៏ដោយ ក៏មេធាវីការពារក្តី នួន ជា អាចនៅតែរំពឹងថានឹងមានការបង្ហាញទឡ្ហីករណ៍តាមផ្លូវច្បាប់ឲ្យបានខ្លាំងក្លាជាងនេះ នៅចំពោះមុខសាលាក្តីនេះ។

7. ទីប្រាំ ការខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់រដ្ឋាភិបាលកម្ពុជាក្នុងការកំណត់ថាខុសច្បាប់ចំពោះការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយពួកខ្មែរក្រហម ពិតជាមានភាពពាក់ព័ន្ធមិនអាចប្រកែកបាន។ យ៉ាងហោចណាស់ ទស្សនៈរបស់សហព្រះរាជអាជ្ញាដែលថា ការហាមឃាត់តាមផ្លូវច្បាប់ដែលអនុម័តដោយស្ថាប័ននីតិបញ្ញត្តិកម្ពុជា "មិនពាក់ព័ន្ធ" ទេ ដោយសារ អ.វ.ត.ក ពុំមែនជា "តុលាការតំណាងសាធារណមតិ" នោះ នាំឲ្យមានការងឿងឆ្ងល់ដែរ[30]។ មេធាវីការពារក្តីសូមលើកឡើងថា វាជាប្រយោជន៍សម្រាប់យុត្តិធម៌ ក្នុងការវិនិច្ឆ័យទៅលើការបទប្រកាន់ក្នុងដីកាដំណោះស្រាយឲ្យបានកាន់តែច្រើនតាមតែអាចធ្វើទៅបាន មុនពេលរដ្ឋាភិបាលបច្ចុប្បន្នចាប់ផ្តើមដាក់ទោសព្រហ្មទណ្ឌប្រឆាំងនឹង នួន ជា និងអ្នកគាំទ្រគាត់ចំពោះការអះអាងថាមិនមានធ្វើខុសនោះ។ សហព្រះរាជអាជ្ញាមិនបានខិតខំប្រឹងប្រែងដើម្បីបង្ហាញតាមវិធីផ្សេងទៀតទេ។

8. មេធាវីការពារក្តីកត់សម្គាល់ថា មួយសប្តាហ៍បន្ទាប់ពីខ្លួនបានដាក់សារណាបន្ថែម ១១ ថ្ងៃបន្ទាប់ពីលោក ហ៊ុន សែន ផ្តល់យោបល់ឲ្យមានការរៀបរៀងសេចក្តីព្រាងច្បាប់មួយក្នុងពិធីជាសាធារណៈមួយនោះ *ច្បាប់ប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ត្រូវបានអនុម័តដោយរដ្ឋ

---

28 ឯកសារលេខ **E163/5/11**, "សេចក្តីសន្និដ្ឋានបឋមពាក់ព័ន្ធនឹងច្បាប់ជាធរមាន", ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣, កថាខណ្ឌ ៥, ១៨ ដល់ ២១ និង ជើងទំព័រ ៣៩។

29 បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ៣៥។

30 ចម្លើយតប, កថាខណ្ឌ ៣៧។

សភា ដោយពុំមានការពិភាក្សាដេញដោលទេ[31]។ មួយរយៈខ្លីក្រោយមក ច្បាប់នេះក៏ត្រូវបានអនុម័ត ដោយព្រឹទ្ធសភាដែរ[32]។ ការព្រួយបារម្ភជាអវូបិយដែលមេធាវីការពារក្ដីបានលើកឡើងនៅក្នុងសារណាបន្ថែមក៏បានក្លាយជាការរារាំងជាខ្លាំងដល់លទ្ធភាពរបស់ នួន ជា ក្នុងការប្រកាសពីការមិនបានប្រព្រឹត្តខុសរបស់ខ្លួន។ តាមន័យជាក់ស្ដែងនោះ សច្ចាធារណ៍នីរទោសដែលគេតែងលើកឡើងអះអាងនោះ[33] លែងអនុវត្តបានចំពោះ នួន ជា តាមច្បាប់កម្ពុជា ដែល អ.វ.ត.ក ជាស្ថាប័នមួយក្រោមច្បាប់នោះទៀតហើយ។ ជាថ្មីម្ដងទៀត ដំណើរការហាមឃាត់ពេលថ្មីៗនេះរបស់នាយករដ្ឋមន្ត្រីក្នុងការបង្កើតច្បាប់សម្រាប់ប្រទេសក្នុងរយៈពេលពីរសប្ដាហ៍បែបនេះក៏បង្ហាញដែរថា[34] អាចមានការបំពារបំពានអំណាចនៅកម្ពុជា ជាពិសេសពាក់ព័ន្ធនឹងពួកអ្នកប្រឆាំងនឹងរដ្ឋាភិបាល។ គេមិនត្រូវមើលរំលងសក្ដានុពលក្នុងការប្រើច្បាប់ថ្មីនេះតាមអំពើចិត្តដែលនឹងប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការសន្មតថាគ្មានទោសបានទេ[35]។

9. ដោយមានសំអាងហេតុទាំងនេះ មេធាវីការពារក្ដីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក. **ទទួលយក** សារណាតបនេះ។

---

[31] មាស សុខជា "រដ្ឋសភាបានអនុម័តច្បាប់ប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងរបប ប៉ុល ពត ដែលមានរិះគន់យ៉ាងខ្លាំងដោយមិនបានពិភាក្សាដេញដោល" ('Without debate, Assembly passes heavily criticised denial law'), កាសែត ភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៣។

[32] ជាង សុខា "ជនរងគ្រោះដាក់ពាក្យបណ្ដឹងប្រឆាំងនឹង "អ្នកមិនទទួលស្គាល់អំពើឧក្រិដ្ឋកម្មក្នុងរបប ប៉ុល ពត"" ('Victims file suit against "denier"'), កាសែត ភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

[33] ចម្លើយតប, កថាខណ្ឌ ១២។

[34] ដូចដែលអង្គជំនុំជម្រះបានដឹងហើយថា មេធាវីការពារក្ដីធ្លាប់បានពណ៌នាពីបញ្ហាទាំងនេះយ៉ាងពិស្ដាររួចមកហើយ។ សម្រាប់ជាឧទាហរណ៍មួយ *សូមមើល* ឯកសារលេខ **E189**, "សំណើសុំឱ្យមានវិធានការជាបន្ទាន់ អនុលោមតាមវិធាន ៣៥", ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ២ ដល់ ១៥ និង ប្រភពឯកសារជាច្រើនដែលបានដកស្រង់នៅក្នុងនោះ។

[35] *សូមមើលឧទាហរណ៍* Paolo Lobba, "ការមិនទទួលយកជាបទល្មើសព្រហ្មទណ្ឌហួសពីការសម្លាប់រង្គាល៖ យោបល់មួយចំនួនចំពោះសេចក្ដីសម្រេចរបស់សហគមន៍អឺរ៉ុបលេខ 2008/913/JHA ស្ដីពីការប្រកាន់ពូជសាសន៍ និង ការស្អប់ជនបរទេស" ('Criminalizing Negationism Beyond the Holocaust: Some Comments on the EU Framework Decision 2008/913/JHA on Racism and Xenophobia') ផ្នែកទី ៥ (ភាសាអង់គ្លេស)។

ខ. **បដិសេធ** ទឡ្ហីករណ៍នានានៅក្នុងចម្លើយតប។ និង

គ. **ទទួលយក** សំណូមពរដែលមាននៅក្នុងបណ្តឹងសាទុក្ខ។

**សហមេធាវីការពារក្តី នួន ជា**

សុន អារុណ Victor KOPPE